ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភា រដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៦៨
ចុះថ្ងៃទី១៨ខែកញ្ញាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៦៧
ចុះថ្ងៃទី០៦ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន
២- លោក វ៉ាន់ ស៊ិន ជាចៅក្រម
៣- លោក ទេវៀល មួន ជាចៅក្រម
៤- លោក ជីវ កេង ជាចៅក្រម
៥- លោក សោមសិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

លោក ជួន ស៊ុនលេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៥៦៤ ចុះថ្ងៃទី២៤ ខែ សីហា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២២០ ចុះថ្ងៃទី៨ ខែ ឧសភា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សោម ភិរុណ អាយុ ៤៧ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើការនៅការិយាល័យជលផលខេត្ត ទីលំនៅភូមិ ផ្សារឆ្នាំង សង្កាត់ទី ១ ទីរួមខេត្ត កំពង់ឆ្នាំង. ឪពុកឈ្មោះ សោម សារ៉ាត "ស" ម្តាយឈ្មោះ ម៉ុត នីន "រ" ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ លឹម គិ អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅភូមិ ផ្សារឆ្នាំង សង្កាត់ទី ១ ទីរួមខេត្ត កំពង់ឆ្នាំង . ឪពុកឈ្មោះ អ៊ឹង ហៀង "ស" ម្តាយឈ្មោះ ខា សុខ "ស" ។

__កម្មវត្ថុបណ្តឹង__ : ប្តឹងទាមទារសិទ្ធិប្រើប្រាស់ និង ការពារលំនៅដ្ឋាន

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី ២៤.៨.៩៨ របស់ឈ្មោះ សោម ភិរុណ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៦៤ ចុះថ្ងៃទី២៤.០៨.១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៨ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី០១.៧.៩៥ របស់ដើមចោទឈ្មោះ លឹម តិ ប្តឹងពីឈ្មោះ សោម ភិរុណ បានប្រើប្រាស់ដំបូលផ្ទះលំនៅដ្ឋានស្របច្បាប់របស់ខ្លួនតាមទំនើងចិត្តហើយសព្វថ្ងៃនេះមានការបែកស្រាំជ្រាបទឹកហូរធ្លាក់ចុះមកក្រោមពាសពេញក្នុងល្វែងផ្ទះបណ្តាលអោយបាត់បង់ភាពអនាម័យ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី២៣.១១.៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង សំរេចចំពោះមុខដើមចោទ និង ចុងចោទ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១_ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_អោយឈ្មោះ សោម ភិរុណ " ចុងចោទ " បញ្ឈប់ការបំពារបំពានយកដំបូលផ្ទះកម្មសិទ្ធិរបស់ឈ្មោះ លឹម តិ " ដើមចោទ " ប្រើប្រាស់ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣_អោយឈ្មោះ សោម ភិរុណ យកសំភារៈឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃចេញអោយអស់ក្នុងរយៈពេល ៧ថ្ងៃ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ ទោះជាមានបណ្តឹងឧទ្ធរណ៍ ដោយ ។

៤_អោយឈ្មោះ លឹម តិ " ដើមចោទ " មានសិទ្ធិដំណើរការជួសជុលកែលំអរដំបូលផ្ទះលំនៅដ្ឋានផ្ទាល់ខ្លួន ចាប់ពីក្រោយពេលប្រកាសសាលក្រមរយៈពេល ៧ថ្ងៃ ។

៥_អោយចុងចោទ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍ អោយចុងចោទ សងប្រាក់ប្រដាប់ក្តី ៧០០០រៀល ទៅដើមចោទវិញ និង ពន្ធសមាមាត្រ៣០០០០០០គុណ ១/១០០ : ៣០០០០រៀល បន្ថែមទៀត ពន្ធសមាមាត្រ៣០០០០គុណ ៨០/១០០ :២៤០០០រៀល ដែលត្រូវដាក់ចូលថវិការដ្ឋ និង ហិបប្រាក់ក្រឡាបញ្ជីក្នុងតម្លៃជា ៣០០០០គុណ ២០/១០០ : ៦០០០រៀល ។

- ពន្ធសមាមាត្រនេះត្រូវអោយដើមចោទ បង់ជាមុនសិន រួចទើបអោយចុងចោទ បង់ជាក្រោយ ។

- តាមមាត្រា ២ ,៣ នៃច្បាប់ភូមិបាល ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ និង ចុងចោទ ។

បើភាគីណាមួយមិនសុខចិត្តអាចប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៥៣ ចុះថ្ងៃទី២៣.១១.៩៥ របស់ឈ្មោះសោម ភិរុណ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី ២៣.១១.៩៥ របស់តុលាការខេត្តកំពង់ឆ្នាំងលើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥០៥ ចុះថ្ងៃទី ២០.៧.៩៨ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣.១១.៩៤ របស់ឈ្មោះ សោម ភិរុណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី២៣.១១.៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល គឺពន្ធហ៊្លឹង.និង ពន្ធចុះបញ្ជីក្តី ចំនួន ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំនួន ៤៥០រៀល និង ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១០០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់នឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៣១ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ របស់ឈ្មោះ សោម ភិរុណ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៥០៥ ចុះថ្ងៃទី ២០.៧.៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៦៤ ចុះថ្ងៃទី ២៤.៨.៩៨ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ០៤.៨.៩៨ របស់ឈ្មោះ សោម ភិរុណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ ៥០៥ ចុះថ្ងៃទី ២០.៧.៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី ២៤.៨.៩៨ របស់ឈ្មោះ សោម ភិរុណ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៦៤ ចុះថ្ងៃទី ២៤.០៨.១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ១៣.១០.៩៨ របស់ឈ្មោះ សោម ភិរុណ

បានឃើញសារណាតប ចុះថ្ងៃទី ២០.១០.៩៨ របស់ឈ្មោះ លឹម គិ

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :-

សាលដីការដ្ឋប្បវេណីលេខ ៥៦៤ ចុះថ្ងៃទី ២៤.៨.៩៨របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

--- ៤---

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ សោម ភិរុណ ជាចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ លឹម តិ ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈ ខ្លួនបានមករស់នៅលើផ្ទះលេខ ០៣អឺស្សៀ នៅចុងឆ្នាំ ១៩៨៩ ពេលនោះផ្ទះនេះស្ថិតនៅជាផ្ទះជួលពីលោក កែវ សួសាក់ នៅឡើយទេ ដោយនៅពីលើផ្ទះលេខ ០៣អឺស្សៀនេះគឺជាន់អឺ១ ជាការិយាល័យផលផលខេត្តកំពង់ឆ្នាំង ។ លុះដល់ពាក់កណ្តាលឆ្នាំ ១៩៩១ ទើបខ្លួន ទិញផ្ទះល្វែងលេខ ០៣អឺស្សៀ នៅផ្សារក្រោមនេះ ពីលោកកែវ សួសាក់ ដើម្បីកាន់កាប់រស់នៅជាកម្មសិទ្ធិចាប់ពីថ្ងៃទី ២៩.០៥.៩១តទៅ ។ ក្រោយមកការិយាល័យផលផលខេត្ត ក៏បានរើចេញពីទីតាំងជាន់អឺ១ និងអឺ២ ទៅកន្លែងថ្មី ដោយបានបែងចែកការិយាល័យនេះអោយបុគ្គលិក ។បន្ទាប់មកខ្លួន បានទិញពីលោកកែវថាយ នូវផ្ទះល្វែងលេខ ០៣អឺ១ ដែលជាអតីតការិយាល័យផលផលខេត្ត ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោក សោម ភិរុណ និង ចម្លើយរបស់លោកលឹម តិ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី ២៥.៨.៩៨ របស់លោក សោម ភិរុណ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា លោក សោម ភិរុណ ត្រូវបានគណៈកម្មាធិការខេត្តកំពង់ឆ្នាំង ប្រគល់ផ្ទះល្វែងជាន់ទី ២ លេខ ៥អោយរួចហើយៗ ការដែលលោកទាមទារសិទ្ធិប្រើប្រាស់ដំបូលផ្ទះទំនាស់ដែលនៅជាប់គ្នានោះគឺជាការខុសឆ្គងពីព្រោះតេរ៉ាស់ទំនាស់នេះជាដំបូលផ្ទះរបស់ដើមចោទ ។
- យល់ឃើញថា លោក សោម ភិរុណ ធ្លាប់បានប្រើប្រាស់ដំបូលផ្ទះទំនាស់នោះខ្លះៗ ក៏ពិតមែន ប៉ុន្តែលោក សោម ភិរុណ ពុំបានចូលរួមជួយថែរក្សាជួសជុលអោយបានគត់មត់ពីសុវត្ថិភាពដល់អ្នកដែលនៅខាងក្រោមឡើយ ហើយដែលវានឹងអាចបង្កអោយមានគ្រោះថ្នាក់នៅពេលខាងមុខ ។
- យល់ឃើញថា លោក សោម ភិរុណ បានធ្វើសារណាការពាររឿងក្តីរបស់លោក ជូនមកតុលាការកំពូល រួចហើយ ប៉ុន្តែលោក ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។
- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥៦៥ ចុះថ្ងៃទី ២៥.៨.៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

--- ៥---

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោក សោម ភិរុណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៥៦៤ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- ទីបរួសប្រាក់ប្រដាប់ក្តីដែលលោក លឹម តិ បានបង់ជូនទៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវអោយលោក សោម ភិរុណ សងប្រាក់ ១៩.០០០រៀលនេះទៅលោក លឹម តិ វិញ ។

បង្គាប់អោយលោក សោម ភិរុណ បង់ពន្ធសមាមាត្រ តាមការកំណត់របស់តុលាការខេត្ត កំពង់ឆ្នាំង ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ ១៩៩៩ ។